# ពិធីសារ

## ដើម្បី

## ទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្មការជួញដូរមនុស្ស
## ជាពិសេសស្ត្រី និងកុមារ
## បំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ
## ស្តីពីការប្រឆាំងបទឧក្រិដ្ឋឆ្លងដែនដែលមានអង្គការចាត់តាំង


Downloaded from http://www.khmerlaws.com

Downloaded from http://www.khmerlaws.com

# ព្រះរាជក្រម

នស/រកម/០១០៦/០០៤

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៥/០០២ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៥ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកិច្ចការនារី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានិងរបស់រដ្ឋមន្ត្រីក្រសួងកិច្ចការនារី

## ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការអនុម័តយល់ព្រម ឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគី នៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង ដែលរដ្ឋសភាបានអនុម័ត កាលពីថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានអនុម័តយល់ស្របលើទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គ លើកទី ១០ នីតិកាលទី ១ ដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖



Downloaded from http://www.khmerlaws.com

# ច្បាប់
# ស្តីពី
# ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃពិធីសារស្តីពី ការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារដែលបំពេញបន្ថែមលើអនុសញ្ញារបស់អង្គការសហប្រជាជាតិ ស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែនដែលមានអង្គការចាត់តាំង

**មាត្រា ១.-**

អនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃពិធីសារស្តីពីការទប់ស្កាត់ បង្ក្រាប និងដាក់ទណ្ឌកម្ម ការជួញដូរមនុស្ស ជាពិសេសស្ត្រីនិងកុមារ ដែលបំពេញបន្ថែមលើ អនុសញ្ញារបស់អង្គការសហប្រជាជាតិស្តីពីការប្រឆាំងបទឧក្រិដ្ឋកម្មឆ្លងដែន ដែលមាន អង្គការចាត់តាំង ដែលអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិក្នុងសម័យប្រជុំ លើកទី ៥៥ តាមសេចក្តីសម្រេចលេខ ៥៥/២៥ ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០០ នៅទីក្រុង ញូវយ៉ក ហើយដែលព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាចូលជាភាគី នាថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០០១ ដូចមានអត្ថបទទាំងស្រុងភ្ជាប់មកជាមួយនេះ ។

**មាត្រា ២.-**

រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវបន្តរាល់នីតិវិធីដើម្បីអនុវត្តពិធីសារ នេះ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៦

នស.០៧០៦.០២២

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**ហ៊ុន សែន**

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី

**រដ្ឋមន្ត្រីក្រសួងកិច្ចការនារី**

**ហត្ថលេខា**

**អ៊ឹង កន្ថាផាវី**

លេខៈ ៣៧៩.ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ.ថ្ងៃទី ២៤.ខែ កក្កដា ឆ្នាំ២០០៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**



Downloaded from http://www.khmerlaws.com

# ពិធីសារដើម្បីធ្វើការទប់ស្កាត់ បង្ក្រាប និង ការដាក់ទណ្ឌកម្ម
# លើការជួញដូរមនុស្សជាពិសេស លើស្ត្រី និង កុមារ
# និងការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិ
# ប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង

**អត្ថបទដែលដកស្រង់ពីច្បាប់ដើម ការថតចម្លងនេះត្រូវបាន**
**បញ្ជាក់អះអាងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ**
**នឹងត្រូវបានគេចេញផ្សាយនៅពេលក្រោយ**

អង្គការសហប្រជាជាតិ
2000



Downloaded from http://www.khmerlaws.com

# ពិធីសារដើម្បីធ្វើការទប់ស្កាត់ បង្ក្រាប និង ការដាក់ទណ្ឌកម្ម លើការជួញដូរមនុស្សជាពិសេស លើស្ត្រី និង កុមារ និងការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង

## បុព្វកថា

### បណ្តារដ្ឋជាសមាជិកទាក់ទិនទៅនឹងពិធីសារនេះ

ការប្រកាសនូវសកម្មភាពដ៏មានប្រសិទ្ធិភាពដើម្បីការពារ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្សជាពិ-សេសស្ត្រី និងកុមារ តម្រូវអោយមានការដោះស្រាយយ៉ាងទូលំទូលាយជាលក្ខណៈអន្តរជាតិ នៅតាមបណ្តាប្រទេសដើម ការឆ្លងកាត់ និងគោលដៅ ដោយរាប់បញ្ចូលទាំងបណ្តាវិធានការមួយចំនួនដើម្បីទប់ស្កាត់នូវអំពើជួញដូរមនុស្ស ការដាក់ទណ្ឌកម្មចំពោះអ្នកជួញដូរមនុស្ស ហើយនិងការពារជនរងគ្រោះពីការជួញដូរនេះ ដោយរាប់បញ្ចូលទាំងកិច្ចការពារសិទ្ធិរបស់ពួកគេដែលត្រូវបានទទួលស្គាល់ជា លក្ខណៈអន្តរជាតិ ។

ទទួលខុសត្រូវនូវការពិត បើទោះបីជាមានអត្ថិភាពផ្សេងៗគ្នានៃការគ្រប់គ្រង ថែរក្សា ឯកសារច្បាប់ជាលក្ខណៈអន្តរជាតិក៏ដោយ ក៏ត្រូវតែអនុវត្តនូវរាល់បណ្តាវិធានការដើម្បីប្រឆាំងលើការជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ដែលមិនទាន់មានឯកសារច្បាប់ជាទុទៅណាមួយដែលប្រឈមមុខរាល់ទិដ្ឋភាពនៃការជួញដូរមនុស្សនៅឡើយ ។

ទាក់ទិនទៅនឹងឯកសារច្បាប់ដែលមិនទាន់មានគ្រប់ជ្រុងជ្រោយ រាល់ជនទាំងឡាយណាដែលទទួលរងនូវអំពើជួញដូរ នឹងមិនត្រូវបានគេការពារអោយបានពេញលេញនៅឡើយ ។

ការរំលឹកឡើងវិញនូវសេចក្តីសម្រេចចិត្តរបស់សន្និបាតអង្គការសហប្រជាជាតិលេខ ៥៣/១១១ ចុះថ្ងៃទី ០៩ ខែ ១២ ឆ្នាំ ១៩៩៨ ដែលមហាសន្និបាតបានសម្រេច បង្កើតឡើងនូវអន្តររដ្ឋាភិបាលដោយមិនទាន់បានកំណត់នូវគណកម្មាធិការសិទ្ធិមនុស្សក្នុងគោលបំណងពិភាក្សាអោយបានល្អិតល្អន់ ទូលំទូលាយ នូវអនុសញ្ញាអន្តរជាតិប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង និងធ្វើការពិភាក្សាយ៉ាងល្អិតល្អន់រវាងគ្នាទៅវិញទៅមកជាអន្តរជាតិ ដើម្បីប្រឈមមុខទៅនឹងការជួញដូរស្ត្រី និងកុមារ ។

ជឿជាក់ថាការបំពេញបន្ថែមនូវអនុសញ្ញាអង្គការសហប្រជាជាតិ ប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង ជាមួយនិងឯកសារច្បាប់អន្តរជាតិក្នុងកិច្ចការពារ ទប់ស្កាត់ និងការដាក់ទណ្ឌកម្មដល់ការជួញដូរមនុស្សជាពិសេសលើស្ត្រី និងកុមារ និងមានផលប្រយោជន៍ក្នុងកិច្ចការពារ ព្រមទាំងប្រយុទ្ធប្រឆាំងទៅនឹងបទឧក្រិដ្ឋនោះ ។

បានព្រមព្រៀងគ្នាដូចខាងក្រោមនេះ:

## I_បទបញ្ញត្តិទូទៅ

### មាត្រា ១

ការទាក់ទិនជាមួយនិងអនុសញ្ញាអង្គការសហប្រជាជាតិប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែនដែលបានចាត់តាំងឡើង:

១-ការបំពេញបន្ថែមនូវអនុសញ្ញារបស់អង្គការសហប្រជាជាតិនៃពិធីសារនេះប្រឆាំងទៅនឹងបទឧក្រិដ្ឋកម្មឆ្លងដែននឹងត្រូវបានបកស្រាយរួមគ្នាជាមួយនឹងអនុសញ្ញា ។

២-រាល់បទបញ្ញត្តិនៃអនុសញ្ញានឹងមានប្រសិទ្ធិភាពដោយមានការផ្លាស់ប្តូរសមស្របទៅនឹងពិធីសារនេះលុះត្រាតែត្រូវបានគេចែងកងនេះ ។



Downloaded from http://www.khmerlaws.com

៣-រាល់បទល្មើសដែលគេបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៥ នៃពិធីសារនេះនឹងត្រូវបានគេចាត់ទុកថាជាបទល្មើសដែលបានបង្កើតឡើងដោយយោងទៅតាមអនុសញ្ញាខាងលើ ។

## មាត្រា ២
## គោលបំណងនៃសេចក្តីថ្លែងការ

គោលបំណងនៃពិធីសារនេះគឺ:

a-ការពារ និងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស ជាពិសេសយកចិត្តទុកដាក់យ៉ាងសំខាន់ទៅលើស្ត្រី និងកុមារ ។

b-ការពារ និងជួយដល់ជនរងគ្រោះដោយសារការជួញដូរ សំខាន់ត្រូវគោរពនូវសិទ្ធិរបស់ពួកគេអោយបានពេញ-លេញ ហើយនិង

c-ជម្រុញនូវកិច្ចសហប្រតិបត្តិការក្នុងចំណោមបណ្តារដ្ឋដែលជាសមាជិក ដើម្បីប្រឈមមុខទៅនឹងបញ្ហាទាំងនោះ

## មាត្រា ៣
## ការប្រើប្រាស់នូវពាក្យសំពី

សម្រាប់គោលបំណងនៃពិធីសារនេះ:

a-អំពើជួញដូរមនុស្ស គឺសំដៅទៅលើ ការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូន ការផ្លាស់ប្តូរទីកន្លែងសំចត ឬក៏ទទួលអោយមនុស្សចូលដោយតាមមធ្យោបាយគំរាមកំហែង ឬការប្រើប្រាស់កម្លាំងឬក៏បែបបទនៃការបង្ខិតបង្ខំផ្សេងទៀតនៃការចាប់ជំរិត ការក្លែងបន្លំ ការឆបោក ការប្រើអំណាចដោយរំលោភបំពាន ឬក៏ការធ្វើអោយមានការឈឺចាប់ ឬក៏ការផ្តល់អោយ ឬក៏ទទួលនូវការចំណាយ ឬអត្ថប្រយោជន៍ ដើម្បីសម្រេចនូវការយល់ព្រមនៃមនុស្សណាម្នាក់ដែលមានការដែលមានការត្រួតពិនិត្យទៅលើមនុស្សម្នាក់ផ្សេងទៀតក្នុងគោលបំណងធ្វើអាជីវកម្ម ។ ការធ្វើអាជីវកម្មរាប់បញ្ចូលទាំងផ្នែកអប្បបរមានៃការធ្វើអាជីវកម្មលើស្រីពេស្យា និងស្ត្រីផ្សេងទៀត ឬបែបបទដទៃទៀតនៃការធ្វើអាជីវកម្មលើផ្លូវភេទដោយចាប់បង្ខំលើកម្លាំងពលកម្ម ឬសេវាកម្ម ទាសភាព ឬការប្រព្រឹត្តនោះប្រហាក់ប្រហែលទៅនឹងទាសភាព សេវគតិភាព ឬក៏ការផ្លាស់ប្តូរសរីរាង្គ ។

b-ការព្រមព្រៀងនៃជនរងគ្រោះដោយការជួញដូរមនុស្ស មានគោលបំណងធ្វើអាជីវកម្មដែលបានកំណត់ទុកក្នុងវាក្យខ័ណ្ឌ (a) នៃមាត្រានេះនឹងមិនទាក់ទងទៅនឹងមធ្យោបាយណាមួយដូចបានកំណត់ក្នុងវាក្យខ័ណ្ឌ (a) ដែលបានប្រើប្រាស់។

c-ការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូន ការផ្លាស់ប្តូរទីកន្លែងសំចត ឬបង្កាន់ដៃក្មេងចូលក្នុងគោលបំណងធ្វើអាជីវកម្ម នឹងត្រូវបានគេចាត់ទុកថាជាការជួញដូរមនុស្ស ទោះបីជាករណីនេះមិនមានជាប់ពាក់ព័ន្ធចូលក្នុងមធ្យោបាយណាមួយដូចដែលបានកំណត់ទុកក្នុងវាក្យខ័ណ្ឌ (a) នៃមាត្រានេះ។

d-កុមារ គឺសំដៅទៅលើមនុស្សណាម្នាក់ដែលមានអាយុក្រោម ១៨ ឆ្នាំ ។

## មាត្រា ៤
## វិសាលភាពនៃការស្នើសុំ

ពិធីសារនេះនឹងត្រូវអនុវត្ត លើកលែងតែមាត្រាដែលគ្មានចែងក្នុងនេះ ដើម្បីធ្វើការការពារ ការស៊ើបអង្កេត និងការកាត់ទោស នៃបទល្មើសទាំងឡាយដែលត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រា ៥ នៃពិធីសារនេះដែលបទល្មើសទាំងអស់នោះគឺជាការឆ្លងដែនតាមធម្មតានិងជាប់ពាក់ព័ន្ធទៅនឹងក្រុមឧក្រិដ្ឋជនដែលបានចាត់តាំងឡើងមួយក៏ដូចជាការការពារនូវជនរងគ្រោះនៃបទល្មើសទាំងនេះ ។



Downloaded from http://www.khmerlaws.com

## មាត្រា ៥
## បទឧក្រិដ្ឋកម្មនីយកម្ម

១-រដ្ឋនីមួយៗជាសមាជិកគួរតែអនុម័តច្បាប់នេះ និងមានវិធានការផ្សេងទៀតដែលចាំបាច់ ដើម្បីបង្កើតជាបទល្មើសឧក្រិដ្ឋដូចមានកំណត់ក្នុងមាត្រា ៣ នៃពិធីសារនេះ នៅពេលដែលត្រូវបានគេប្រព្រឹត្តដោយចេតនា ។

២-រដ្ឋនីមួយៗគួរតែអនុម័តនូវច្បាប់នេះ និងមានវិធានការផ្សេងទៀតដែលចាំបាច់ដើម្បីបង្កើតឡើងនូវបទល្មើសឧក្រិដ្ឋ។

a-ប្រធានបទចំពោះទស្សនៈជាមូលដ្ឋាននៃប្រព័ន្ធច្បាប់របស់ខ្លួនមានបំណងដើម្បីប្រព្រឹត្តនូវបទល្មើសដែលបានបង្កើត ឡើងដោយអនុលោមទៅតាមកឋាខ័ណ្ឌ ១ នៃមាត្រានេះ ។

b-ការចូលរួមសមគំនិតក្នុងបទល្មើសមួយដែលបានបង្កើតឡើងដោយអនុលោមទៅតាមកឋាខ័ណ្ឌ ១ នៃមាត្រានេះ ហើយនិង

c-ការចាត់តាំង ឬការចាត់ចែងនូវជនទាំងឡាយណាផ្សេងទៀតអោយប្រព្រឹត្តនូវបទល្មើសមួយដែលត្រូវបានគេបង្កើតឡើង ដោយយោងទៅតាមកឋាខ័ណ្ឌ ១ នៃមាត្រានេះ ។

## II-ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស

## មាត្រា ៦
## ការជួយសង្គ្រោះ និងការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្សខុសច្បាប់

១-នៅក្នុងករណីដែលសមស្រប ហើយនិងវិសាលភាពដែលអាចប្រព្រឹត្តិទៅបាននូវច្បាប់របស់ប្រទេសរៀងៗខ្លួន រដ្ឋនីមួយៗត្រូវការពារដាច់ដោយឡែកនិងអត្តសញ្ញាណរបស់ជនរងគ្រោះដោយអំពើជួញដូរ រាប់បញ្ចូលទាំងការទំនាក់ទំនងទៅវិញទៅមក តាមការបង្កើតឡើងនូវទម្រង់ការច្បាប់ដែលទាក់ទងទៅនឹងការជួញដូរដែលគួរអោយទុកចិត្តបាន ។

២-រដ្ឋនីមួយដែលជាសមាជិកត្រូវតែធានានូវច្បាប់ក្នុងប្រទេសរបស់ខ្លួន ឬក៏ប្រព័ន្ធរដ្ឋបាលដែលមានវិធានការថាផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅតាមករណីសមស្របដូចជាៈ

a-ពត៌មានស្តីពីការទាក់ទិនទៅនឹងតុលាការ និងទម្រង់ការផ្នែករដ្ឋបាល

b-ការជួយផ្តល់មធ្យោបាយ តាមទស្សនរបស់គេ ហើយនិងការទាក់ទងនោះនឹងត្រូវផ្តល់អោយព្រមទាំងពិនិត្យពិច័យទៅតាមដំណាក់កាលសមស្រប នូវទម្រង់បទឧក្រិដ្ឋប្រឆាំងទៅនឹងអ្នកប្រព្រឹត្តល្មើសក្នុងលក្ខណៈមួយដែលមិនធ្វើអោយប៉ះពាល់ដល់សិទ្ធិនៃកិច្ចការពារ ។

៣-រដ្ឋនីមួយៗជាសមាជិកត្រូវពិចារណានូវការអនុវត្តវាលវិធានការ ដើម្បីផ្តល់អោយដល់ជនរងគ្រោះដែលរួចផុតពីអំពើជួញដូរមនុស្ស ទាំងផ្លូវចិត្ត ផ្លូវកាយ និងសង្គមរស់នៅ រួមមានទាំងករណីសមស្របទៅក្នុងកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងបណ្តាអង្គការពាក់ព័ន្ធ ហើយនិងសង្គមស៊ីវិលផ្សេងទៀត និងជាពិសេសបទបញ្ញត្តិដែលមានចែងដូចខាងក្រោមនេះ :

a-មានទីលំនៅសមរម្យ

b-ការផ្តល់យោបល់ និងពត៌មានក្នុងករណីចាំបាច់នៃសិទ្ធិស្របច្បាប់របស់ពួកគេក្នុងភាសាមួយដែលជនរងគ្រោះដោយអំពើជួញដូរអាចយល់បាន ។

c-ជំនួយទាំងផ្នែកវេជ្ជសាស្ត្រ ហើយនិងផ្នែកសំភារៈ ហើយនិង

d-ផ្តល់នូវឱកាសអោយមានការធ្វើការងារ ការសិក្សា និងការបណ្តុះបណ្តាល



Downloaded from http://www.khmerlaws.com

៤-រដ្ឋនីមួយៗជាសមាជិកត្រូវទទួលខុសត្រូវក្នុងការអនុវត្តបញ្ញត្តិនៃមាត្រានេះ អាយុ ភេទ និងសេចក្តីត្រូវការជាចាំបាច់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សខុសច្បាប់ ជាពិសេសតម្រូវការចាំបាច់របស់កុមារដោយរាប់បញ្ចូលទាំងការស្នាក់នៅដ៏សមរម្យ ការអប់រំ និងការថែទាំ ។

៥-រដ្ឋនីមួយៗដែលជាសមាជិកត្រូវខិតខំខ្នះខ្នែង ដើម្បីផ្តល់អោយនូវសុវត្ថិភាពផ្នែកផ្លូវកាយដល់ជនរងគ្រោះ ក្នុងខណៈដែលពួកគេស្ថិតក្នុងបូរណភាពទឹកដីរបស់ខ្លួន ។

៦-រដ្ឋនីមួយៗដែលជាសមាជិកត្រូវធានានូវប្រព័ន្ធច្បាប់ប្រទេសរបស់ខ្លួននូវវិធានការ ដែលផ្តល់ដល់ជនរងគ្រោះដោយអំពើជួញដូរមនុស្សទៅតាមលទ្ធភាពដែលអាចទទួលបាននូវប្រាក់សំណងចំពោះការខូចខាតពីការឈឺចាប់នេះ ។

## មាត្រា ៧

## ស្ថានភាពរបស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សក្នុងរដ្ឋជាម្ចាស់ផ្ទះ

១-លើសពីនេះទៅទៀតដើម្បីចាត់នូវវិធានការដែលទាក់ទិនទៅនឹងមាត្រាទី ៦ នៃពិធីសារនេះ រដ្ឋនីមួយៗជាសមាជិកត្រូវពិចារណាពីការអនុម័តច្បាប់ ឬក៏វិធានការសមស្របដែលអនុញ្ញាតអោយជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅតែនៅជាបណ្តោះអាសន្ន ឬជាអចិន្ត្រៃយ៍ នៅក្នុងបូរណភាពដែនដីរបស់ខ្លួនទៅតាមករណីសមស្រប ។

២-ក្នុងការអនុវត្តន៍នូវបទបញ្ញត្តិដែលបានចែងក្នុងកថាខ័ណ្ឌ ១ នៃមាត្រានេះរដ្ឋនីមួយៗជាសមាជិកត្រូវផ្តល់នូវការពិចារណាអោយសមស្របចំពោះកិច្ចការមនុស្សធម៌ និងក្តីមេត្តាអាណិតអាសូរ ។

## មាត្រា ៨

## ការធ្វើមាតុភូមិនិវត្តន៍នៃជនរងគ្រោះដោយអំពើជួញដូរ

១-រដ្ឋដែលជាសមាជិកនៃជនរងគ្រោះដោយអំពើជួញដូរមនុស្សមានសញ្ជាតិរបស់ខ្លួន ឬក៏ជាមនុស្សដែលមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ នៅពេលដែលចូលទៅក្នុងបូរណភាពទឹកដីរបស់រដ្ឋជាម្ចាស់ផ្ទះ ដែលជាសមាជិកត្រូវផ្តល់ភាពងាយស្រួលនិងទទួលដោយធានានូវសុវត្ថិភាពដល់ជននោះ ហើយអោយការវិលត្រឡប់ជននោះដោយគ្មានពន្យាពេលអោយជ្រុលហួសហេតុ ឬក៏មិនសមហេតុផល ។

២-នៅពេលដែលរដ្ឋមួយជាសមាជិក បញ្ជូនជនរងគ្រោះដោយអំពើជួញដូរមនុស្ស ត្រឡប់ទៅអោយរដ្ឋជាម្ចាស់ដើមវិញដែលជាសមាជិកមួយទៀតដែលជនរងគ្រោះនោះ តាមសញ្ជាតិដែលគេមាន នៅពេលដែលចូលទៅក្នុងបូរណភាពទឹកដីនៃរដ្ឋជាម្ចាស់ផ្ទះ សិទ្ធិនៃការស្នាក់នៅជាអចិន្ត្រៃយ៍ ត្រូវបានធានាសុវត្ថិភាពនៃការវិលត្រឡប់មកវិញរបស់ជននោះ ហើយនិងចំពោះទម្រង់ការច្បាប់ផ្សេងៗដែលពាក់ព័ន្ធទៅនឹងអង្គហេតុពិតនៃជននោះ
គឺពិតជាជាជនរងគ្រោះដោយអំពើជួញដូរ ហើយពេញចិត្តដោយធ្វើការវិលត្រឡប់វិញ។

៣-សេចក្តីស្នើសុំរបស់រដ្ឋដែលជាម្ចាស់ផ្ទះបានធ្វើសំណូមពរដល់រដ្ឋជាសមាជិកមួយទៀត និងមិនត្រូវធ្វើការពន្យាពេលអោយជ្រុលហួសហេតុ ឬក៏មិនសមហេតុផល បញ្ជាក់ថាជនដែលរងគ្រោះដោយអំពើជួញដូរមានសញ្ជាតិរបស់ខ្លួន ឬក៏មានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍ក្នុងបូរណភាពទឹកដីរបស់ខ្លួន នៅមុនពេលដែលចូលមកក្នុងបូរណភាពទឹកដីរបស់រដ្ឋជាម្ចាស់ផ្ទះ។

៤-ដើម្បីផ្តល់ភាពងាយស្រួលដល់ការវិលត្រឡប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្សខុសច្បាប់ ដែលពួកគេគ្មានឯកសារត្រឹមត្រូវរដ្ឋជាសមាជិកដែលជនរងគ្រោះមានសញ្ជាតិខ្លួននោះគេមានសិទ្ធិស្នាក់នៅជាអចិន្ត្រៃយ៍នៅពេលដែលចូលក្នុងដែនដីនៃការគ្រប់គ្រងរបស់រដ្ឋជាម្ចាស់ផ្ទះនិងយល់ព្រមចេញអោយប្រើប្រាស់ទៅតាមសំណូមពររបស់រដ្ឋជាម្ចាស់ផ្ទះដូចជាឯកសារទាំងឡាយ តាមសំណើររបស់រដ្ឋជាម្ចាស់ផ្ទះ ឬការផ្តល់សិទ្ធិផ្សេងទៀតដែលចាំបាច់អោយជននោះវិលត្រឡប់ទៅកន្លែងដើមរបស់គេវិញ ។

៥-មាត្រានេះនឹងគ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់ការផ្តល់សិទ្ធិណាមួយចំពោះជនរងគ្រោះដោយអំពើនៃការជួញដូរមនុស្សតាមច្បាប់របស់ប្រទេសណាមួយនៃរដ្ឋដែលជាម្ចាស់ផ្ទះ ។



Downloaded from http://www.khmerlaws.com

៦-មាត្រានេះមិនគ្មានអ្វីដែលធ្វើអោយប៉ះពាល់ដល់ការអនុវត្តន៍នៃកិច្ចព្រមព្រៀងណាមួយជាទ្វេភាគី ឬពហុភាគី ឬក៏ការចាត់ចែងដោយគ្រប់គ្រងទាំងមូល ឬផ្នែកខ្លះនៃការវិលត្រឡប់របស់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ។

## III-ការការពារ កិច្ចសហប្រតិបត្តិការនិងវិធានការផ្សេងៗ

### មាត្រា ៩

### ការការពារជនរងគ្រោះដោយអំពើជួញដូរ

១-បណ្តារដ្ឋដែលជាសមាជិកត្រូវបង្កើតនូវកិច្ចការពារការជួញដូរមនុស្ស គោលនយោបាយ និងវិធានការផ្សេងៗ អោយបានទូលំទូលាយ :

ក-ទប់ស្កាត់ ហើយនិងប្រយុទ្ធប្រឆាំងទៅនឹងការជួញដូរមនុស្ស និង

ខ-ការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស ជាពិសេសស្ត្រី និងកុមារ ពីការធ្វើអោយគេរងគ្រោះឡើងវិញ ។

២-បណ្តារដ្ឋដែលជាសមាជិកត្រូវខិតខំខ្នះខ្នែង ដើម្បីទទួលខុសត្រូវនូវបណ្តាវិធានការទាំងឡាយដូចជា ធ្វើការស្រាវជ្រាវពតិមាន ហើយនិងយុទ្ធនាការផ្សព្វផ្សាយតាមរយៈធាតុអាកាសគ្រប់ទិសទីក្នុងសង្គមព្រមទាំងធ្វើការផ្តួចផ្តើមផ្នែកសេដ្ឋកិច្ចជាលើកដំបូង ដើម្បីទប់ស្កាត់ និងប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ។

៣-រាល់កម្មវិធីនយោបាយ និងបណ្តាវិធានការផ្សេងៗទៀត ដែលត្រូវបានបង្កើតឡើងដោយអនុលោមទៅតាមមាត្រានេះ អោយបានសមស្របដោយរាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល ឬក៏អង្គការដទៃទៀតដែលពាក់ព័ន្ធព្រមទាំងសមាសភាពសង្គមស៊ីវិលផ្សេងៗទៀត ។

៤-បណ្តារដ្ឋដែលជាសមាជិកត្រូវចាត់ ឬពង្រឹងនូវបណ្តាវិធានការដោយរាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដើម្បីជួយសម្រួលដល់កត្តាដែលធ្វើអោយមនុស្ស ជាពិសេសស្ត្រី និងកុមារដែលងាយរងនូវឈឺចាប់ដោយអំពើជួញដូរ ដូចជាភាពក្រីក្រ ការមិនទាន់មានភាពរីកចម្រើនពេញលេញ និងគ្មាននូវឱកាសស្មើភាពគ្នា ។

៥-បណ្តារដ្ឋដែលជាសមាជិកត្រូវអនុម័ត និងពង្រឹងនីតិបញ្ញត្តិ ឬបណ្តាវិធានការផ្សេងៗ ដូចជាវិធានការលើការអប់រំសង្គម ឬក៏ផ្នែកវប្បធម៌ដោយរាប់បញ្ចូលទាំងកិច្ចសហប្រតិបត្តិការទ្វេភាគី ឬពហុភាគី ដើម្បីរារាំងពីតម្រូវការដែលជម្រុញអោយមានការទាញយកផលប្រយោជន៍ពីមនុស្សជាច្រើនទម្រង់ ជាពិសេសស្ត្រី និងកុមារដែលនាំមុខគេក្នុងអំពើជួញដូរ ។

### មាត្រា ១០

### ការផ្លាស់ប្តូរពត៌មាន និងការបណ្តុះបណ្តាល

១-ការអនុវត្តន៍ច្បាប់ផ្នែកអន្តោប្រវេសន៍ ឬអាជ្ញាធរដទៃទៀតដែលពាក់ព័ន្ធនៃបណ្តារដ្ឋជាសមាជិក ចាំបាច់ត្រូវធ្វើកិច្ចសហប្រតិបត្តិការអោយបានសមស្របជាមួយអាជ្ញាធរផ្សេងទៀត តាមការផ្លាស់ប្តូរពតិមានដោយអនុលោមទៅតាមច្បាប់ប្រទេសរបស់គេ ដើម្បីអោយពួកគេធ្វើការសម្រេចចិត្ត :

ក-ប្រសិនបើបុគ្គលម្នាក់ធ្វើការឆ្លងកាត់ ឬមានបំណងឆ្លងកាត់ព្រំដែនអន្តរជាតិដោយប្រើប្រាស់ឯកសារធ្វើដំណើរដែលជាកម្មសិទ្ធរបស់អ្នកដទៃ ឬក៏គ្មានឯកសារធ្វើដំណើរ ជាអ្នកប្រព្រឹត្តនូវបទឧក្រិដ្ឋ ឬជនរងគ្រោះដោយអំពើជួញដូរខុសច្បាប់ ។

ខ-រាល់ប្រភេទនៃឯកសារធ្វើដំណើរដែលបុគ្គលម្នាក់ៗបានប្រើប្រាស់ ឬមានបំណងនឹងប្រើប្រាស់ដើម្បីឆ្លងកាត់ព្រំដែនអន្តរជាតិ ក្នុងគោលបំណងជួញដូរមនុស្សខុសច្បាប់ និង



Downloaded from http://www.khmerlaws.com

៤- រាល់មធ្យោបាយ និងវិធីដែលបានប្រើប្រាស់ដោយក្រុមឧក្រិដ្ឋជនដែលបានចាត់តាំងឡើង ក្នុងគោលបំណងជួញដូរមនុស្ស ដោយរួមមានទាំងការជ្រើសរើសសមាជិកថ្មី ការដឹកជញ្ជូនជនរងគ្រោះតាមផ្លូវ ព្រមទាំងទាក់ទិនទៅនឹងក្រុមមនុស្សដែលពាក់ព័ន្ធ ក្នុងករណីជួញដូរមនុស្ស ត្រូវចាត់វិធានការទៅតាមលទ្ធភាព ដើម្បីស្រាវជ្រាវរកជនទាំងនោះ ។

២-បណ្តារដ្ឋដែលជាសមាជិកត្រូវផ្តល់អោយ ឬក៏ពង្រីកការបណ្តុះបណ្តាលសម្រាប់អនុវត្តច្បាប់ផ្នែកអន្តោប្រវេសន៍ និងបណ្តាមន្ត្រីដែលពាក់ព័ន្ធដទៃទៀតក្នុងកិច្ចការពារនូវអំពើជួញដូរមនុស្សខុសច្បាប់ ។ វគ្គបណ្តុះបណ្តាលនឹងត្រូវផ្តោតទៅលើរបៀបនៃការប្រើប្រាស់ក្នុងកិច្ចការពារនូវអំពើជួញដូរមនុស្ស កាត់ទោសចំពោះអ្នកទាំងឡាយណាដែលជួញដូរមនុស្ស ហើយនិងការការពារសិទ្ធិរបស់ជនរងគ្រោះរួមមានទាំងកិច្ចការពារជនរងគ្រោះពីអ្នកជួញដូរមនុស្សខុសច្បាប់ ។ វគ្គបណ្តុះ-បណ្តាលក៏នឹងមានការចាំបាច់ទទួលខុសត្រូវផងដែរ ដោយពិចារណាទៅលើសិទ្ធិមនុស្ស ហើយនិងកុមារ បញ្ហាស្រើបស្រាលផ្លូវភេទ ហើយនិងជម្រុញអោយមានកិច្ចសហប្រតិបត្តិការជាមួយអង្គការក្រៅរដ្ឋាភិបាល និងអង្គការដែលពាក់ព័ន្ធទៅនឹងសង្គមស៊ីវិលដទៃទៀត ។

៣-រដ្ឋមួយដែលជាសមាជិកទទួលបាននូវពត៌មាន នឹងត្រូវធ្វើទៅតាមសេចក្តីស្នើសុំដោយរដ្ឋមួយដែលជាសមាជិកដែលបានបញ្ជូនពត៌មានទៅតាមទីកន្លែងជាក់លាក់ស្តីពីការប្រើប្រាស់របស់ខ្លួន។

## មាត្រា ១១
## វិធានការព្រំដែន

១-ដោយមិនប្រកាន់ពូជសាសន៍ក្នុងការប្តេជ្ញាចិត្តជាអន្តរជាតិ ក្នុងទំនាក់ទំនងចលនាសេរីភាពមនុស្សរដ្ឋជាសមាជិកនឹងត្រូវពង្រឹងអោយអស់លទ្ធភាពដូចជា ករណីត្រួតពិនិត្យព្រំដែនដែលអាចនឹងមានការចាំបាច់ ដើម្បីការពារ និងរកអោយឃើញអំពើជួញដូរមនុស្សខុសច្បាប់ ។

២-បណ្តារដ្ឋជាសមាជិកនីមួយៗ នឹងត្រូវអនុម័តច្បាប់ ឬវិធានការដ៏ប្រសើរដើម្បីការពារអោយអស់លទ្ធភាពមធ្យោបាយដឹកជញ្ជូនដោយអាជីពពាណិជ្ជកម្ម ការប្រើប្រាស់នៅក្នុងបេសកកម្មនៃបទល្មើសដែលបង្កើតឡើងអនុលោមទៅតាមមាត្រាទី ៥ នៃពិធីសារនេះ ។

៣-គ្រប់ទីកន្លែងដែលសមស្រប និងគ្មានការប្រកាន់ពូជសាសន៍ដែលអនុវត្តបានទៅតាមអនុសញ្ញាអន្តរជាតិ វិធានការទាំងនេះរួមមាន ការបង្កើតនូវកាតព្វកិច្ច នៃអាជីពពាណិជ្ជកម្ម ក្នុងនោះមានក្រុមហ៊ុនដឹកជញ្ជូនផ្សេងៗ ឬម្ចាស់ក្រុមហ៊ុន ឬជាអ្នកអនុវត្តនូវមធ្យោបាយនៃការដឹកជញ្ជូននានា រកអោយឃើញប្រាកដថាអ្នកធ្វើដំណើរទាំងនោះ តម្រូវអោយមានឯកសារផ្ទាល់ខ្លួនក្នុងការចូលទៅរដ្ឋជាម្ចាស់ផ្ទះ ។

៤- បណ្តារដ្ឋជាសមាជិកនីមួយៗត្រូវអនុវត្តវិធានការចាំបាច់អនុលោមទៅតាមច្បាប់ក្នុងស្រុករបស់ខ្លួន ដើម្បីផ្តល់ការដាក់ទណ្ឌកម្មសេដ្ឋកិច្ច ក្នុងករណីមានការរំលោភលើកាតព្វកិច្ចដែលបានចែងក្នុងវគ្គ ៣ នៃមាត្រានេះ ។

៥- បណ្តារដ្ឋជាសមាជិកត្រូវធ្វើការពិចារណា អនុវត្តនូវវិធានការដែលបានអនុញ្ញាត យោងទៅតាមច្បាប់របស់ខ្លួនការបដិសេធមិនអោយចូល ឬការលុបចោលទិដ្ឋាការរបស់អ្នកស្នើសុំ ក្នុងបេសកកម្មនៃបទល្មើសដែលបង្កើតឡើងយោងតាមពិធីសារនេះ ។

៦-យោងតាមមាត្រាទី ៧ នៃអនុសញ្ញានេះដោយមិនប្រកាន់ពូជសាសន៍ រដ្ឋជាសមាជិកនីមួយៗ នឹងត្រូវពិចារណាក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការរវាងភ្នាក់ងារត្រួតពិនិត្យព្រំដែន នៅក្នុងនោះដោយមានការបង្កើត និងរក្សានូវទំនាក់ទំនងផ្ទាល់ ។

## មាត្រា ១២
## ការត្រួតពិនិត្យឯកសារ និងសន្តិសុខ

បណ្តារដ្ឋជាសមាជិកនីមួយៗ ត្រូវអនុវត្តវិធានការទាំងនេះក្នុងករណីចាំបាច់ជាមួយមធ្យោបាយដែលមាន


Downloaded from http://www.khmerlaws.com

ឧ-ត្រូវបញ្ជាក់អោយច្បាស់នូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណដែលចេញដោយមានគុណភាពដែលគេមិនងាយ បន្លំក្នុងការប្រើប្រាស់ និងមិនអាចធ្វើក្លែងក្លាយ ឬកែប្រែអោយខុសច្បាប់ ថតចម្លង ឬចេញ និង

៦-ធានានូវបូរណភាព និងសុវត្ថិភាពនៃការចេញអោយប្រើនូវឯកសារធ្វើដំណើរ ឬអត្តសញ្ញាណ ឬក្នុងនាមរដ្ឋជា សមាជិក និងការទប់ស្កាត់ភាពមិនស្របច្បាប់របស់គេ ការធានា និងការប្រើប្រាស់ ។

## មាត្រា ១៣

## ធម្មនុញ្ញភាព និងសុពលភាពនៃឯកសារ

តាមសំណូមពរនៃរដ្ឋជាសមាជិកមួយ និងរដ្ឋជាសមាជិកផ្សេងទៀត និងយោងទៅតាមច្បាប់នៅក្នុងរដ្ឋរបស់ខ្លួនបញ្ជាក់ពេលវេលាអោយច្បាស់លាស់នៃធម្មនុញ្ញភាព និងសុពលភាពនៃឯកសារធ្វើដំណើរ ឬអត្តសញ្ញាណដែលបានចេញ ឬអះអាងអោយមានការប្រើប្រាស់នៅក្នុងនាមរបស់ខ្លួន និងបានសង្ស័យ ឬក៏កំពុងប្រើប្រាស់ក្នុងអំពើជួញដូរមនុស្ស ។

# IV-អវសានបញ្ញត្តិ

## មាត្រា ១៤

## ខសន្យារក្សាទុក (ខគម្រិតព្រំដែននិរាករណ៍)

១-គ្មានអ្វីក្នុងពិធីសារនេះដែលនាំអោយប៉ះពាល់ដល់សិទ្ធ កាតព្វកិច្ច ការទទួលខុសត្រូវនៃបណ្តារដ្ឋ ឬបុគ្គល នៅក្រោមច្បាប់អន្តរជាតិនេះ រួមមានច្បាប់មនុស្សធម៌អន្តរជាតិ និងច្បាប់សិទ្ធិមនុស្សអន្តរជាតិ ហើយជាពិសេសដែលអាចអនុវត្តបាន ក្នុងអនុសញ្ញាឆ្នាំ ១៩៥១ និងពិធីសារឆ្នាំ ១៩៦៧ ដែលទាក់ទងទៅនឹងឋានៈជាជនភៀសខ្លួន និងគោលការណ៍ច្បាស់លាស់ដូចមានចែងក្នុងនោះ ។

២-វិធានការដែលបានកំណត់ទុកក្នុងពិធីសារនេះនឹងត្រូវបកស្រាយ និងស្នើសុំនៅក្នុងមធ្យោបាយមួយដែលមិនរើសអើង ចំពោះមនុស្សដែលមានប្រវត្តិថាពួកគេជាជនរងគ្រោះនៃការជួញដូរមនុស្សខុសច្បាប់ ការបកស្រាយ និងការស្នើសុំនៃវិធានការទាំងនោះ និងមានជាមួយគោលការណ៍នៃការទទួលស្គាល់ជាលក្ខណៈអន្តរជាតិមិនប្រកាន់ពូជសាសន៍ ។

## មាត្រា ១៥

## ដំណោះស្រាយវិវាទ

១-បណ្តារដ្ឋជាសមាជិកត្រូវខិតខំប្រឹងប្រែងក្នុងការដោះស្រាយវិវាទដែលទាក់ទងទៅនឹងការបកស្រាយ និងការស្នើសុំតាមរយៈការចរចារនៅក្នុងពិធីសារនេះ ។

២-រាល់វិវាទទាំងឡាយដែលកើតមានឡើងរវាងរដ្ឋជាសមាជិកដែលទាក់ទងទៅនឹងការបកស្រាយ និងការស្នើសុំនៃពិធីសារនេះដែលមិនអាចដោះស្រាយបានតាមរយៈការចរចារនៅក្នុងពេលវេលាដ៏សមហេតុផលមួយ តាមរយៈនៃការស្នើសុំនៃរដ្ឋមួយ ឬបណ្តារដ្ឋទាំងនោះត្រូវបានដាក់ស្នើទៅអាជ្ញាកណ្តាលប្រសិនបើរយៈពេល ៦ ខែ បន្ទាប់ពីថ្ងៃដែលបានដាក់សំណើរទៅអាជ្ញាកណ្តាល បណ្តារដ្ឋជាសមាជិកទាំងនោះដែលមិនអាចនឹងយល់ព្រមតាមការចាត់ចែងរបស់អាជ្ញាកណ្តាលនោះ រដ្ឋណាមួយក្នុងចំណោមនេះអាចដាក់វិវាទនោះទៅតុលាការយុត្តិធម៌អន្តរជាតិ ដោយស្នើសុំអនុលោមតាមលក្ខណៈច្បាប់របស់តុលាករនោះ ។

៣-រដ្ឋជាសមាជិកនីមួយៗអាចនៅពេលដែលចុះហត្ថលេខាដល់សច្ចានុម័ត ការទទួល ឬការស្នើសុំ ឬដែលបានកំណត់ក្នុងពិធីសារនេះ ប្រកាសថាមិនអាចធ្វើការពិចារណាដោយខ្លួនឯងដែលមាននៅក្នុងវគ្គ ២នៃមាត្រានេះ ហើយបណ្តារដ្ឋជាសមាជិកដទៃទៀត និងមិនអាចយោងតាមវគ្គ ២ នៃមាត្រានេះដោយមានការគោរពទៅរដ្ឋជាសមាជិកមួយផ្សេងទៀតដែលបានធ្វើតាមការកំណត់លក្ខខ័ណ្ឌទាំងនេះ ។

៤-រដ្ឋជាសមាជិកណាមួយដែលបានធ្វើការកំណត់លក្ខខ័ណ្ឌ ដែលយោងតាមវគ្គ ៣ នៃមាត្រានេះ នឹងអាចដកនូវការកំណត់លក្ខខ័ណ្ឌនេះពេលណាក៏បានដោយធ្វើការបញ្ជាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

## មាត្រា ១៦



Downloaded from http://www.khmerlaws.com

## ការចុះហត្ថលេខា ការផ្តល់សច្ចាប័ន ការយល់ព្រមសេចក្តីស្នើសុំ និងការទទួលថែម

១-ពិធីសារនេះនឹងបើកចំហរទៅដល់បណ្តារដ្ឋទាំងអស់សម្រាប់ការចុះហត្ថលេខាពីថ្ងៃទី ១២-១៥ ខែ ១២ ឆ្នាំ ២០០០ នៅទីក្រុង ប៉ាលើមូ ប្រទេសអ៊ីតាលី ហើយបន្ទាប់មកនៅឯទីស្នាក់ការអង្គការសហប្រជាជាតិនៅទីក្រុង ញូយក រហូតដល់ថ្ងៃទី ១២ ខែ ១២ ឆ្នាំ ២០០២ ។

២-នៅក្នុងពិធីសារនេះនឹងបើកចំហរផងដែរចំពោះការចុះហត្ថលេខាដោយ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ អោយតែយ៉ាងហោយណាស់រដ្ឋជាសមាជិកមួយនៃអង្គការនេះបានចុះហត្ថលេខាលើពិធីសារនេះដោយយោងទៅតាមវគ្គ ១ នៃមាត្រានេះ ។

៣-ពិធីសារនេះគឺមានកម្មវត្ថុក្នុងការធ្វើសច្ចាប័ន ការយល់ព្រម និងការទទួលយកវិធានការនៃការធ្វើសច្ចាប័ន ការទទួលយក ឬការយល់ព្រមនឹងដាក់ជូនទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ ត្រូវចាត់វិធានការនៃការធ្វើសច្ចាប័នរបស់ខ្លួន ការទទួលយក ឬការយល់ព្រមយ៉ាងហោចណាស់សមាជិកនៃរដ្ឋមួយរបស់ខ្លួនត្រូវបានធ្វើដូច្នេះដែរ ។ ក្នុងវិធានការនៃការធ្វើសច្ចប័ននេះ ការទទួលយក ឬការយល់ព្រមអង្គការនោះនឹងត្រូវប្រកាសពីការខិតខំប្រឹងប្រែង តាមសមត្ថភាពរបស់ខ្លួនដោយមានការគោរពពាល់បែបបទដែលគ្របដណ្តប់ ក្នុងពិធីសារនេះ អង្គការនោះនឹងត្រូវជម្រាបផងដែរ ដល់អ្នកទទួលឯកសារនៃការពាក់ព័ន្ធទូវ ការបញ្ជាក់អះអាងនៃសមត្ថភាពខិតខំប្រឹងប្រែងរបស់ខ្លួន ។

៤-ពិធីសារនេះនឹងបើកចំហរក្នុងការទទួលយកដោយរដ្ឋណាមួយ ឬដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ណាមួយ ក្នុងនោះយ៉ាងហោចណាស់ រដ្ឋជាសមាជិកមួយ ដែលជាភាគីនៃពិធីសារនេះ ត្រូវចាត់វិធានការនៃការទទួលយកត្រូវបានដាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នៅពេលដែលមានការទទួលយល់ព្រមរបស់ខ្លួន អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ត្រូវប្រកាសពីសមត្ថភាពរបស់ខ្លួន ដោយគោរពទៅលើបែបបទដែលគ្របដណ្តប់ពិធីសារនេះ ។ អង្គការតាំងនេះក៏ត្រូវជម្រាបផងដែរទៅអ្នកកាន់ឯកសារ ពាក់ព័ន្ធការបញ្ជាក់អះអាងណាមួយតៅតាមសមត្ថភាពរបស់ខ្លួន

## មាត្រា ១៧

## ការចូលជាធរមាន

១-ពិធីសារនេះនឹងចូលជាធរមានក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីដាក់អោយធ្វើសច្ចប័ន រយៈពេល ៤០ ថ្ងៃ ការទទួលយក ឬការយលព្រម ឬការស្នើសុំ លើកលែងតែថា វាមិនអាចចូលជាធរមាន មុនការចូលជាធរមាននៃអនុសញ្ញានេះ ក្នុងគោលបំណងនៃវគ្គនេះ រាល់វិធានការដែលបានដាក់ដោយអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ នឹងមិនអាចទុកជាលក្ខណៈនៃការដាក់វិធានការបន្ថែមទាំងនោះដោយរដ្ឋជាសមាជិកនៃអង្គការនោះ ។

២-ចំពោះបណ្តារដ្ឋនីមួយៗ ឬអង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់មួយ ការធ្វើសច្ចាប័ន ការទទួល ឬការស្នើសុំ ឬក៏ការទទួលយល់ព្រមនៃពិធីសារនេះ បន្ទាប់ពីចាត់វិធានការរយៈពេល ៤០ ថ្ងៃនៃសកម្មភាពនេះ ។ ពិធីសារនេះនឹងចូលជាធរមានរយៈពេល ៣០ ថ្ងៃ បន្ទាប់ពីថ្ងៃដែលបានដាក់ដោយរដ្ឋ ឬអង្គការនោះ ដែលពាក់ព័ន្ធទៅនឹងវិធានការ ឬនៅថ្ងៃដែលពិធីសារនេះចូលជាធរមានដែលភ្ជាប់ទៅនឹងវគ្គ ១ នៃពិធីសារនេះ ឬក្រោយពីនេះ ។

## មាត្រា ១៨

## ការធ្វើវិសោធនកម្ម

១-បន្ទាប់ពីផុតកំណត់រយៈពេល ៥ ឆ្នាំ ចាប់តាំងពីថ្ងៃចូលជាធរមាននៃពិធីសារនេះ រដ្ឋជាសមាជិកមួយនៃពិធីសារនេះអាចស្នើធ្វើវិសោធនកម្ម នឹងត្រូវដាក់ទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ដែលនិងមាននៅលើទំនាក់ទំនងនៃការស្នើសុំធ្វើវិសោធនកម្ម ទៅបណ្តារដ្ឋដែលជាសមាជិក និងនៅសន្និបាតនៃភាគីទាំងអស់ចំពោះអនុសញ្ញាក្នុងគោលបំណងធ្វើការពិចារណា និងការសម្រេចចិត្តស្តីពីសំណើរនោះ ។ រដ្ឋជាសមាជិកនៃពិធីសារនេះនឹងធ្វើការប្រជុំគ្នានៅឯសន្និសីទ នៃបណ្តាភាគីទាំងអស់ ត្រូវខិតខំប្រឹងប្រែងគ្រប់បែបយ៉ាង ដើម្បីសម្រេចនូវការព្រមព្រៀងនៃការធ្វើវិសោធនកម្មនីមួយៗ ។ ប្រសិនបើរាល់កិច្ចខិតខំប្រឹងប្រែងក្នុងការព្រមព្រៀងមតិត្រូវបានពិភាក្សា ហើយមិនអាចឈានទៅដល់ការព្រមព្រៀង ការធ្វើវិសោធនកម្ម ត្រូវប្រើមធ្យោបាយចុងក្រោយបំផុត តម្រូវអោយមានការអនុម័តរបស់ខ្លួនក្នុងសម្លេងឆ្នោត ២/៣ នៃ



Downloaded from http://www.khmerlaws.com

បណ្តារដ្ឋជាសមាជិកក្នុងពិធីសារនេះបង្ហាញអោយឃើញ ហើយនិងធ្វើការបោះឆ្នោត នៅក្នុងការធ្វើសន្និសីទនៃភាគីទាំងអស់ ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចក្នុងតំបន់ ក្នុងបញ្ហាដែលស្ថិតនៅលើសមត្ថកិច្ចរបស់គេ នឹងត្រូវអនុវត្តនូវសិទ្ធក្នុងការបោះឆ្នោតទៅតាមមាត្រានេះជាមួយនឹងចំនួននៃការបោះឆ្នោតស្មើទៅនឹងចំនួននៃរដ្ឋសមាជិករបស់គេ ដែលស្ថិតនៅក្នុងភាគីនៃពិធីសារនេះ អង្គការទាំងនេះនឹងមិនអាចអនុវត្តនូវសិទ្ធិបោះឆ្នោតរបស់គេ ប្រសិនបើរដ្ឋជាសមាជិករបស់គេអនុវត្តជំនួយ ។

៣-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមវគ្គ ១ នៃមាត្រានេះ ក្នុងកម្មវត្ថុធ្វើសច្ចាប័ន ការយល់-ព្រមទទួល ការស្នើសុំដោយបណ្តារដ្ឋជាសមាជិក ។

៤-ការធ្វើវិសោធនកម្មមួយត្រូវបានអនុម័តយោងទៅតាមវគ្គ ១ នៃមាត្រានេះ នឹងចូលជាធរមានក្នុងការគោរពរដ្ឋជាសមាជិកមួយ រយៈពេល ៩០ ថ្ងៃ ដែលបានដាក់ពាក្យទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ នៃការសុំធ្វើសច្ចាប័ន ការព្រមទទួលយក ឬការស្នើសុំនៃការធ្វើវិសោធនកម្មនេះ ។

៥-នៅពេលដែលការស្នើសុំធ្វើវិសោធនកម្មចូលជាធរមាន វានឹងត្រូវភ្ជាប់ជាមួយបណ្តារដ្ឋជាសមាជិកទាំងនោះដែលបានបង្ហាញការយល់ព្រមរបស់គេ ដែលភ្ជាប់ទៅនឹងច្បាប់នេះ ។ បណ្តារដ្ឋជាសមាជិកដទៃទៀតនឹងត្រូវជាប់នូវបទបញ្ញត្តិពិធីសារនេះ មុននឹងធ្វើវិសោធនកម្មផ្សេងៗដែលគេបានធ្វើសច្ចាប័ន បានទទួល ឬបានស្នើសុំ ។

## មាត្រា ១៩

## ការប្រកាសបដិសេធ

១-រដ្ឋជាសមាជិកមួយអាចប្រកាសបដិសេធនូវពិធីសារនេះ ដោយសរសេរបញ្ជាក់អះអាងទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ការប្រកាសបដិសេធទាំងនេះនឹងមានប្រសិទ្ធិភាពរយៈពេល ១ ឆ្នាំ ក្រោយពីថ្ងៃទទួលនិងធ្វើការបញ្ជាក់ប្រាប់អោយដឹងដោយអគ្គលេខាធិការអង្គការសហប្រជាជាតិ ។

២-អង្គការសមាហរណកម្មសេដ្ឋកិច្ចតំបន់ នឹងលែងជាភាគីនៃពិធីសារនេះ នៅពេលដែលរដ្ឋជាសមាជិករបស់ខ្លួនបានធ្វើការប្រកាសបដិសេធ ។

## មាត្រា ២០

## អ្នកទទួលបញ្ញើ និងការប្រើប្រាស់ភាសា

១-អគ្គលេខាធិការអង្គការសហប្រជាជាតិ គឺជាអ្នកផ្តើមអោយមានអ្នកកាន់បញ្ញើនៃពិធីសារនេះ

២-ច្បាប់ដើមនៃពិធីសារនេះ នៅក្នុងនោះមានភាសា អារ៉ាប់ ចិន អង់គ្លេស បារាំង អេស្បាញ រុស្ស៊ី ។ អត្ថបទទាំងនោះមានតម្លៃដូចគ្នាទៅនឹងច្បាប់ដើម ដែលនឹងបានដាក់តំកល់ទុកនៅអគ្គលេខាធិការអង្គការសហប្រជាជាតិ ។ សាក្សីទាំងអស់ត្រូវចុះហត្ថលេខានៅខាងក្រោមដោយពេលពេញ ផ្តល់សិទ្ធិអំណាចដ៏ត្រឹមត្រូវដោយរដ្ឋាភិបាលរបស់ខ្លួន ត្រូវបានចុះហត្ថលេខាលើពិធីសារនេះ ។



Downloaded from http://www.khmerlaws.com

## Protocol to Prevent, Suppress and Punish Trafficking in Persons Especially Women and Children, supplementing the United Nations Convention against Transnational Organized Crime

**Adopted and opened for signature, ratification and accession by General Assembly resolution 55/25 of 15 November 2000 (not in force)**

**Preamble**

The States Parties to this Protocol,

Declaring that effective action to prevent and combat trafficking in persons, especially women and children, requires a comprehensive international approach in the countries of origin, transit and destination that includes measures to prevent such trafficking, to punish the traffickers and to protect the victims of such trafficking, including by protecting their internationally recognized human rights,

Taking into account the fact that, despite the existence of a variety of international instruments containing rules and practical measures to combat the exploitation of persons, especially women and children, there is no universal instrument that addresses all aspects of trafficking in persons,

Concerned that, in the absence of such an instrument, persons who are vulnerable to trafficking will not be sufficiently protected,

Recalling General Assembly resolution 53/111 of 9 December 1998, in which the Assembly decided to establish an open-ended intergovernmental ad hoc committee for the purpose of elaborating a comprehensive international convention against transnational organized crime and of discussing the elaboration of, inter alia, an international instrument addressing trafficking in women and children,

Convinced that supplementing the United Nations Convention against Transnational Organized Crime with an international instrument for the prevention, suppression and punishment of trafficking in persons, especially women and children, will be useful in preventing and combating that crime,

Have agreed as follows :

### I. General provisions

**Article 1**

Relation with the United Nations Convention against Transnational Organized Crime

1. This Protocol supplements the United Nations Convention against Transnational Organized Crime. It shall be interpreted together with the Convention.

2. The provisions of the Convention shall apply, mutatis mutandis, to this Protocol unless otherwise provided herein.

3. The offences established in accordance with article 5 of this Protocol shall be regarded as offences established in accordance with the Convention.

**Article 2**

**Statement of purpose**

The purposes of this Protocol are:

( a ) To prevent and combat trafficking in persons, paying particular attention to women and children;


Downloaded from http://www.khmerlaws.com

( b ) To protect and assist the victims of such trafficking, with full respect for their human rights; and

( c ) To promote cooperation among States Parties in order to meet those objectives.

**Article 3**

**Use of terms**

For the purposes of this Protocol:

( a ) "Trafficking in persons" shall mean the recruitment, transportation, transfer, harbouring or receipt of persons, by means of the threat or use of force or other forms of coercion, of abduction, of fraud, of deception, of the abuse of power or of a position of vulnerability or of the giving or receiving of payments or benefits to achieve the consent of a person having control over another person, for the purpose of exploitation. Exploitation shall include, at a minimum, the exploitation of the prostitution of others or other forms of sexual exploitation, forced labour or services, slavery or practices similar to slavery, servitude or the removal of organs;

( b ) The consent of a victim of trafficking in persons to the intended exploitation set forth in subparagraph ( a ) of this article shall be irrelevant where any of the means set forth in subparagraph ( a ) have been used;

( c ) The recruitment, transportation, transfer, harbouring or receipt of a child for the purpose of exploitation shall be considered "trafficking in persons" even if this does not involve any of the means set forth in subparagraph ( a ) of this article;

( d ) "Child" shall mean any person under eighteen years of age.

**Article 4**

**Scope of application**

This Protocol shall apply, except as otherwise stated herein, to the prevention, investigation and prosecution of the offences established in accordance with article 5 of this Protocol, where those offences are transnational in nature and involve an organized criminal group, as well as to the protection of victims of such offences.

**Article 5**

**Criminalization**

1. Each State Party shall adopt such legislative and other measures as may be necessary to establish as criminal offences the conduct set forth in article 3 of this Protocol, when committed intentionally.

2. Each State Party shall also adopt such legislative and other measures as may be necessary to establish as criminal offences:

( a ) Subject to the basic concepts of its legal system, attempting to commit an offence established in accordance with paragraph 1 of this article;

( b ) Participating as an accomplice in an offence established in accordance with paragraph 1 of this article; and

( c ) Organizing or directing other persons to commit an offence established in accordance with paragraph 1 of this article.

## II. Protection of victims of trafficking in persons



Downloaded from http://www.khmerlaws.com

**Article 6**

**Assistance to and protection of victims of trafficking in persons**

1. In appropriate cases and to the extent possible under its domestic law, each State Party shall protect the privacy and identity of victims of trafficking in persons, including, inter alia, by making legal proceedings relating to such trafficking confidential.

2. Each State Party shall ensure that its domestic legal or administrative system contains measures that provide to victims of trafficking in persons, in appropriate cases:

( a ) Information on relevant court and administrative proceedings;

( b ) Assistance to enable their views and concerns to be presented and considered at appropriate stages of criminal proceedings against offenders, in a manner not prejudicial to the rights of the defence.

3. Each State Party shall consider implementing measures to provide for the physical, psychological and social recovery of victims of trafficking in persons, including, in appropriate cases, in cooperation with non-governmental organizations, other relevant organizations and other elements of civil society, and, in particular, the provision of:

( a ) Appropriate housing;

( b ) Counselling and information, in particular as regards their legal rights, in a language that the victims of trafficking in persons can understand;

( c ) Medical, psychological and material assistance; and

( d ) Employment, educational and training opportunities.

4. Each State Party shall take into account, in applying the provisions of this article, the age, gender and special needs of victims of trafficking in persons, in particular the special needs of children, including appropriate housing, education and care.

5. Each State Party shall endeavour to provide for the physical safety of victims of trafficking in persons while they are within its territory.

6. Each State Party shall ensure that its domestic legal system contains measures that offer victims of trafficking in persons the possibility of obtaining compensation for damage suffered.

**Article 7**

**Status of victims of trafficking in persons in receiving States**

1. In addition to taking measures pursuant to article 6 of this Protocol, each State Party shall consider adopting legislative or other appropriate measures that permit victims of trafficking in persons to remain in its territory, temporarily or permanently, in appropriate cases.

2. In implementing the provision contained in paragraph 1 of this article, each State Party shall give appropriate consideration to humanitarian and compassionate factors.

**Article 8**

**Repatriation of victims of trafficking in persons**

1. The State Party of which a victim of trafficking in persons is a national or in which the person had the right of permanent residence at the time of entry into the territory of the receiving State Party



Downloaded from http://www.khmerlaws.com

shall facilitate and accept, with due regard for the safety of that person, the return of that person without undue or unreasonable delay.

2. When a State Party returns a victim of trafficking in persons to a State Party of which that person is a national or in which he or she had, at the time of entry into the territory of the receiving State Party, the right of permanent residence, such return shall be with due regard for the safety of that person and for the status of any legal proceedings related to the fact that the person is a victim of trafficking and shall preferably be voluntary.

3. At the request of a receiving State Party, a requested State Party shall, without undue or unreasonable delay, verify whether a person who is a victim of trafficking in persons is its national or had the right of permanent residence in its territory at the time of entry into the territory of the receiving State Party.

4. In order to facilitate the return of a victim of trafficking in persons who is without proper documentation, the State Party of which that person is a national or in which he or she had the right of permanent residence at the time of entry into the territory of the receiving State Party shall agree to issue, at the request of the receiving State Party, such travel documents or other authorization as may be necessary to enable the person to travel to and re-enter its territory.

5. This article shall be without prejudice to any right afforded to victims of trafficking in persons by any domestic law of the receiving State Party.

6. This article shall be without prejudice to any applicable bilateral or multilateral agreement or arrangement that governs, in whole or in part, the return of victims of trafficking in persons.

## III. Prevention, cooperation and other measures

**Article 9**

**Prevention of trafficking in persons**

1. States Parties shall establish comprehensive policies, programmes and other measures:

( a ) To prevent and combat trafficking in persons; and

( b ) To protect victims of trafficking in persons, especially women and children, from revictimization.

2. States Parties shall endeavour to undertake measures such as research, information and mass media campaigns and social and economic initiatives to prevent and combat trafficking in persons.

3. Policies, programmes and other measures established in accordance with this article shall, as appropriate, include cooperation with non-governmental organizations, other relevant organizations and other elements of civil society.

4. States Parties shall take or strengthen measures, including through bilateral or multilateral cooperation, to alleviate the factors that make persons, especially women and children, vulnerable to trafficking, such as poverty, underdevelopment and lack of equal opportunity.

5. States Parties shall adopt or strengthen legislative or other measures, such as educational, social or cultural measures, including through bilateral and multilateral cooperation, to discourage the demand that fosters all forms of exploitation of persons, especially women and children, that leads to trafficking.

**Article 10**

**Information exchange and training**



Downloaded from http://www.khmerlaws.com

1. Law enforcement, immigration or other relevant authorities of States Parties shall, as appropriate, cooperate with one another by exchanging information, in accordance with their domestic law, to enable them to determine:

( a ) Whether individuals crossing or attempting to cross an international border with travel documents belonging to other persons or without travel documents are perpetrators or victims of trafficking in persons;

( b ) The types of travel document that individuals have used or attempted to use to cross an international border for the purpose of trafficking in persons; and

( c ) The means and methods used by organized criminal groups for the purpose of trafficking in persons, including the recruitment and transportation of victims, routes and links between and among individuals and groups engaged in such rafficking, and possible measures for detecting them.

2. States Parties shall provide or strengthen training for law enforcement, immigration and other relevant officials in the prevention of trafficking in persons. The training should focus on methods used in preventing such trafficking, prosecuting the traffickers and protecting the rights of the victims, including protecting the victims from the traffickers. The training should also take into account the need to consider human rights and child- and gender-sensitive issues and it should encourage cooperation with non-governmental organizations, other relevant organizations and other elements of civil society.

3. A State Party that receives information shall comply with any request by the State Party that transmitted the information that places restrictions on its use.

**Article 11**

**Border measures**

1. Without prejudice to international commitments in relation to the free movement of people, States Parties shall strengthen, to the extent possible, such border controls as may be necessary to prevent and detect trafficking in persons.

2. Each State Party shall adopt legislative or other appropriate measures to prevent, to the extent possible, means of transport operated by commercial carriers from being used in the commission of offences established in accordance with article 5 of this Protocol.

3. Where appropriate, and without prejudice to applicable international conventions, such measures shall include establishing the obligation of commercial carriers, including any transportation company or the owner or operator of any means of transport, to ascertain that all passengers are in possession of the travel documents required for entry into the receiving State.

4. Each State Party shall take the necessary measures, in accordance with its domestic law, to provide for sanctions in cases of violation of the obligation set forth in paragraph 3 of this article.

5. Each State Party shall consider taking measures that permit, in accordance with its domestic law, the denial of entry or revocation of visas of persons implicated in the commission of offences established in accordance with this Protocol.

6. Without prejudice to article 27 of the Convention, States Parties shall consider strengthening cooperation among border control agencies by, inter alia, establishing and maintaining direct channels of communication.

**Article 12**

**Security and control of documents**

Each State Party shall take such measures as may be necessary, within available means:


Downloaded from http://www.khmerlaws.com

( a ) To ensure that travel or identity documents issued by it are of such quality that they cannot easily be misused and cannot readily be falsified or unlawfully altered, replicated or issued; and

( b ) To ensure the integrity and security of travel or identity documents issued by or on behalf of the State Party and to prevent their unlawful creation, issuance and use.

**Article 13**

**Legitimacy and validity of documents**

At the request of another State Party, a State Party shall, in accordance with its domestic law, verify within a reasonable time the legitimacy and validity of travel or identity documents issued or purported to have been issued in its name and suspected of being used for trafficking in persons.

## IV. Final provisions

**Article 14**

**Saving clause**

1. Nothing in this Protocol shall affect the rights, obligations and responsibilities of States and individuals under international law, including international humanitarian law and international human rights law and, in particular, where applicable, the 1951 Convention and the 1967 Protocol relating to the Status of Refugees and the principle of non-refoulement as contained therein.

2. The measures set forth in this Protocol shall be interpreted and applied in a way that is not discriminatory to persons on the ground that they are victims of trafficking in persons. The interpretation and application of those measures shall be consistent with internationally recognized principles of non-discrimination.

**Article 15**

**Settlement of disputes**

I. States Parties shall endeavour to settle disputes concerning the interpretation or application of this Protocol through negotiation.

2. Any dispute between two or more States Parties concerning the interpretation or application of this Protocol that cannot be settled through negotiation within a reasonable time shall, at the request of one of those States Parties, be submitted to arbitration. If, six months after the date of the request for arbitration, those States Parties are unable to agree on the organization of the arbitration, any one of those States Parties may refer the dispute to the International Court of Justice by request in accordance with the Statute of the Court.

3. Each State Party may, at the time of signature, ratification, acceptance or approval of or accession to this Protocol, declare that it does not consider itself bound by paragraph 2 of this article. The other States Parties shall not be bound by paragraph 2 of this article with respect to any State Party that has made such a reservation.

4. Any State Party that has made a reservation in accordance with paragraph 3 of this article may at any time withdraw that reservation by notification to the Secretary-General of the United Nations.

**Article 16**

**Signature, ratification, acceptance, approval and accession**



Downloaded from http://www.khmerlaws.com

1. This Protocol shall be open to all States for signature from 12 to 15 December 2000 in Palermo, Italy, and thereafter at United Nations Headquarters in New York until 12 December 2002.

2. This Protocol shall also be open for signature by regional economic integration organizations provided that at least one member State of such organization has signed this Protocol in accordance with paragraph 1 of this article.

3. This Protocol is subject to ratification, acceptance or approval. Instruments of ratification, acceptance or approval shall be deposited with the Secretary-General of the United Nations. A regional economic integration organization may deposit its instrument of ratification, acceptance or approval if at least one of its member States has done likewise. In that instrument of ratification, acceptance or approval, such organization shall declare the extent of its competence with respect to the matters governed by this Protocol. Such organization shall also inform the depositary of any relevant modification in the extent of its competence.

4. This Protocol is open for accession by any State or any regional economic integration organization of which at least one member State is a Party to this Protocol. Instruments of accession shall be deposited with the Secretary-General of the United Nations. At the time of its accession, a regional economic integration organization shall declare the extent of its competence with respect to matters governed by this Protocol. Such organization shall also inform the depositary of any relevant modification in the extent of its competence.

**Article 17**

**Entry into force**

1. This Protocol shall enter into force on the ninetieth day after the date of deposit of the fortieth instrument of ratification, acceptance, approval or accession, except that it shall not enter into force before the entry into force of the Convention. For the purpose of this paragraph, any instrument deposited by a regional economic integration organization shall not be counted as additional to those deposited by member States of such organization.

2. For each State or regional economic integration organization ratifying, accepting, approving or acceding to this Protocol after the deposit of the fortieth instrument of such action, this Protocol shall enter into force on the thirtieth day after the date of deposit by such State or organization of the relevant instrument or on the date this Protocol enters into force pursuant to paragraph 1 of this article, whichever is the later.

**Article 18**

**Amendment**

1. After the expiry of five years from the entry into force of this Protocol, a State Party to the Protocol may propose an amendment and file it with the Secretary-General of the United Nations, who shall thereupon communicate the proposed amendment to the States Parties and to the Conference of the Parties to the Convention for the purpose of considering and deciding on the proposal. The States Parties to this Protocol meeting at the Conference of the Parties shall make every effort to achieve consensus on each amendment. If all efforts at consensus have been exhausted and no agreement has been reached, the amendment shall, as a last resort, require for its adoption a two-thirds majority vote of the States Parties to this Protocol present and voting at the meeting of the Conference of the Parties.

2. Regional economic integration organizations, in matters within their competence, shall exercise their right to vote under this article with a number of votes equal to the number of their member States that are Parties to this Protocol. Such organizations shall not exercise their right to vote if their member States exercise theirs and vice versa.

3. An amendment adopted in accordance with paragraph 1 of this article is subject to ratification, acceptance or approval by States Parties.


Downloaded from http://www.khmerlaws.com

4. An amendment adopted in accordance with paragraph 1 of this article shall enter into force in respect of a State Party ninety days after the date of the deposit with the Secretary-General of the United Nations of an instrument of ratification, acceptance or approval of such amendment.

5. When an amendment enters into force, it shall be binding on those States Parties which have expressed their consent to be bound by it. Other States Parties shall still be bound by the provisions of this Protocol and any earlier amendments that they have ratified, accepted or approved.

**Article 19**

**Denunciation**

1. A State Party may denounce this Protocol by written notification to the Secretary-General of the United Nations. Such denunciation shall become effective one year after the date of receipt of the notification by the Secretary-General.

2. A regional economic integration organization shall cease to be a Party to this Protocol when all of its member States have denounced it.

**Article 20**

**Depositary and languages**

1. The Secretary-General of the United Nations is designated depositary of this Protocol.

2. The original of this Protocol, of which the Arabic, Chinese, English, French, Russian and Spanish texts are equally authentic, shall be deposited with the Secretary-General of the United Nations.

In witness whereof, the undersigned plenipotentiaries, being duly authorized thereto by their respective Governments, have signed this Protocol.



Downloaded from http://www.khmerlaws.com